# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស

ផ្នែកនេះ ពណ៌នាពីសូចនាករសេដ្ឋកិច្ច នៅប្រទេសធំៗមួយចំនួន និងនៅអាស៊ីអាគ្នេយ៍។

នៅត្រីមាសទី២ ផសស ពិត នៅ តំបន់ឥណ្ឌូនេស៊ី កើន ៤,៧% ធៀបនឹងឆ្នាំមុន ដែលជាកំណើនទាបបំផុត នៅត្រីមាសទី២ គិតចាប់ពីឆ្នាំ២០១០ មក។ កំណើននៅម៉ាឡេស៊ី មានកម្រិត ៤,៩% ខ្ពស់ជាងឆ្នាំមុន ប៉ុន្តែកំណើន ផសស ពិតប្រចាំឆ្នាំ ធ្លាក់ចុះ ០,៧ ឯកតាភាគរយ ធៀបត្រីមាសមុន។ ថ្លៃទំនិញ និង តម្រូវការក្នុងស្រុកទាបជាងមុន បានរួមចំណែកបញ្ចុះកំណើន។ កំណើន ផសស ពិត នៅសិង្ហបុរី ធ្លាក់មកត្រឹម ១,៨% ធៀបឆ្នាំមុន និងទាបជាងកម្រិត ២,៦% កាលពីត្រីមាសមុន។ កំណើនពីមួយឆ្នាំទៅមួយឆ្នាំនៅថៃ ឡើងដល់ ២,២% នៅត្រីមាសទី២ ធៀបនឹង ០,៣% កាលពីឆ្នាំមុន។ វិនិយោគសាធារណៈ និងទេសចរណ៍ ចូលរួមចំណែកចម្បងនៅក្នុងកំណើននេះ។ កំណើន ផសស ពិត ពីមួយឆ្នាំទៅមួយឆ្នាំ នៅវៀតណាម ឡើងដល់ ៦,៥%។

កំណើន ផសស នៅចិន និងហុងកុង ធ្លាក់ចុះបន្តិចមកត្រឹម ៧,០% និង ២,៨% រៀងគ្នា ក្នុងត្រីមាសទី២។ កំណើននៅកូរ៉េខាងត្បូង ធ្លាក់មកត្រឹម ២,២% ហើយនៅតៃវ៉ាន់ ធ្លាក់មកត្រឹម ០,៥%។ ការធ្លាក់ចុះអត្រាកំណើននៅតៃវ៉ាន់ បណ្តាលជាចម្បងមកពីការធ្លាក់ចុះការនាំចេញ។

នៅត្រីមាសទី២ កំណើន ផសស នៅសហភាពអឺរ៉ុប ឡើងដល់ ១,២% ធៀបនឹង ០,៧% កាលពីឆ្នាំមុន។ ផសស ពិត នៅជប៉ុន កើន ០,៧% ធៀបឆ្នាំមុន។ នៅត្រីមាសនេះ សេដ្ឋកិច្ចជប៉ុន អាចបញ្ចប់ការរួមចុះ ហើយត្រឡប់ជាមានកំណើនវិញ ដោយសារប្រាក់យ៉េនធ្លាក់ថ្លៃ ប៉ុន្តែដំណើរបែបនេះមិនមែនជា ដំណោះស្រាយសម្រាប់ ការងើបសេដ្ឋកិច្ចឡើងវិញក្នុងរយៈពេលវែងនោះទេ។ កំណើន ផសស ពិត នៅសហរដ្ឋអាមេរិក ធ្លាក់ចុះបន្តិច មកត្រឹម ២,៣% ធៀបនឹង ២,៦% កាលពីឆ្នាំមុន។ កំណើននេះជំរុញឡើងដោយវិស័យសេវាកម្ម ជាពិសេស ការថែទាំសុខភាព និងការដឹកជញ្ជូន។

## អតិផរណាក្នុងពិភពលោក និងអត្រាប្តូរប្រាក់

អតិផរណានៅប្រទេសអ្នកមានមួយចំនួន មានកម្រិតទាបជាងការរំពឹងទុក ហើយប្រទេសខ្លះត្រូវប្រឹងប្រយុទ្ធនឹងបរិត្តផរណា។

អតិផរណានៅកម្ពុជានៅថេរ ត្រឹម ១,០% ធៀបឆ្នាំមុន។ សាំងចុះថ្លៃ នាំឲ្យអតិផរណាធ្លាក់ចុះ។ អតិផរណានៅឥណ្ឌូនេស៊ីឡើងដល់ ៧,១% ធៀបនឹង ៦,៦% កាលពីត្រីមាសមុន។ កម្រិតនិងភាពឆាប់ប្រែប្រួលនៃអតិផរណានៅឥណ្ឌូនេស៊ី វាខ្លាំងក្លាជាងនៅបណ្តាប្រទេស មានសេដ្ឋកិច្ចកំពុងផុសឡើងស្រដៀងៗគ្នា។ សិង្ហបុរី បានជួបបរិត្តផរណាបីត្រីមាសជាប់ៗគ្នាកន្លងមក។ នៅត្រីមាសទី២ បរិត្តផរណានៅសិង្ហបុរី មានដល់ ០,៤% ដែលជាកម្រិតទាបបំផុតក្នុងពេល ៤ឆ្នាំកន្លងមក។ នៅត្រីមាសទី២ ថៃក៏មានបរិត្តផរណាដល់ ១,១% ដែរ រីឯនៅវៀតណាម អតិផរណាធ្លាក់ចុះមកត្រឹម ១,០% ធៀបនឹង ៤,៧% កាលពីឆ្នាំមុន។

អតិផរណានៅតែមានកម្រិតទាបនៅប្រទេសចិន និងនៅប្រទេសខ្លាអាស៊ីឯទៀត។ នៅចិន អតិផរណាកើនឡើងបន្តិច ដល់ ១,៤% ដោយសារការឡើងថ្លៃអាហារ។ អតិផរណារួមចុះមកត្រឹម ៣,១% នៅហុងកុង និង ០,៥% នៅកូរ៉េខាងត្បូង។ តៃវ៉ាន់ជួបនឹងបរិត្តផរណាដល់ ០,៧%។ អតិផរណាក្នុងតំបន់ចាយប្រាក់អឺរ៉ូ ឡើងដល់ ០,២% ឯនៅជប៉ុន វាធ្លាក់ចុះមកត្រឹម ០,៥% ហើយនៅសហរដ្ឋអាមេរិក វាកើនពី -០,៤% មកដល់សូន្យ។

នៅត្រីមាសទី២ ប្រាក់រៀល ធ្លាក់ថ្លៃ ០,៧% ធៀបនឹង ឆ្នាំមុន ទល់នឹងប្រាក់ដុល្លារ មកត្រឹម ៤០៥៦,៧រៀល/ដុល្លារ។ ប្រាក់បាតថៃ ធ្លាក់ថ្លៃ ២,៥% ធៀបនឹងឆ្នាំមុន ទល់នឹងប្រាក់ដុល្លារ ហើយប្រាក់ដុងវៀតណាម ធ្លាក់ថ្លៃ ៣,៨%។ ប្រាក់យន់ចិន ឡើងថ្លៃ ០,៥% ទល់នឹងប្រាក់ ដុល្លារ ធៀបនឹងឆ្នាំមុន រីឯប្រាក់យេនជប៉ុន ធ្លាក់ថ្លៃ ១៨,៩%។

## ថ្លៃទំនិញនៅលើទីផ្សារពិភពលោក

នៅត្រីមាសទី២ ទំនិញសំខាន់ៗក្នុងទីផ្សារពិភពលោក ធ្លាក់ថ្លៃ បើធៀបនឹងឆ្នាំមុន។ ពោត ធ្លាក់ថ្លៃ ២១,៦% មកត្រឹម ១៦៨,៤ដុល្លារ/តោន។ ប្រេងដូងប្រេង ធ្លាក់ថ្លៃ ២៥,២% មកត្រឹម ៦៦៤.០ដុល្លារ/តោន ហើយកៅស៊ូ ធ្លាក់ថ្លៃ ១៤,២% មកត្រឹម ១៥២៥,៩ដុល្លារ/តោន។ អង្ករ ធ្លាក់ថ្លៃ ៣,៧% ហើយសណ្តែកសៀង ធ្លាក់ថ្លៃ ៣០,៤%។ ប្រេងឆៅ ធ្លាក់ថ្លៃ ៤២,៩% មកត្រឹម ៦០,៥ដុល្លារ/ធុង ដែលនាំឲ្យប្រេងសាំង និងប្រេងម៉ាស៊ូត ធ្លាក់ថ្លៃអស់ ៣៣,៩% និង ៣៧,២% រៀងគ្នា។

អត្ថបទនេះ រៀបរៀងដោយលោកស្រី ស្រ៊ី បុប្ផារ័ត្ន ជាអ្នកស្រាវជ្រាវ និងលោកស្រី ប៊ុន ដូរីណា ជាជំនួយការស្រាវជ្រាវ នៅវិទ្យាស្ថាន CDRI។

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស

តារាង១. កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៧-២០១៥ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 10.2 | 6.7 | 0.1 | 6.0 | 7.1 | 7.3 | 7.4 | - | - | - | - | - |
| ឥណ្ឌូណេស៊ី | 6.3 | 6.1 | 4.2 | 6.2 | 6.5 | 6.3 | 5.8 | 5.2 | 5.1 | 5.0 | 5.4 | 4.7 |
| ម៉ាឡេស៊ី | 6.3 | 4.6 | -2.4 | 9.0 | 4.9 | 5.4 | 4.6 | 6.2 | 6.4 | 5.6 | 5.8 | 5.6 |
| សិង្ហបុរី | 7.7 | 1.1 | -4.5 | 14.7 | 4.7 | 1.3 | 3.8 | 5.1 | 2.4 | 2.4 | 2.1 | 2.6 |
| ថៃ | 4.9 | 2.6 | 3.3 | 7.9 | 0.0 | 6.7 | 2.8 | 3.1 | 0.3 | 0.6 | 2.2 | 3.3 |
| វៀតណាម | 8.5 | 6.2 | 4.7 | 6.4 | 6.2 | 5.2 | 5.4 | - | - | - | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 11.9 | 9.0 | 8.2 | 10.4 | 9.3 | 7.7 | 7.7 | 7.1 | 7.5 | 7.3 | 7.3 | 7.1 |
| ហុងកុង | 6.4 | 2.4 | -3.2 | 6.9 | 4.9 | 2.9 | 3.0 | 2.5 | 1.8 | 2.7 | 2.2 | 2.1 |
| កូរ៉េខាងត្បូង | 4.9 | 2.2 | -1.0 | 6.1 | 3.6 | 2.1 | 2.8 | 4.1 | 3.5 | 3.2 | 2.8 | 2.4 |
| តៃវ៉ាន់ | 5.2 | 0.1 | -3.6 | 11.1 | 4.2 | 1.2 | 2.2 | 3.1 | 3.7 | 3.8 | 3.3 | 3.4 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 2.9 | 0.9 | -3.8 | 1.6 | 1.6 | -0.5 | 0.1 | 0.9 | 0.7 | 0.3 | 0.9 | 1.0 |
| ជប៉ុន | 2.0 | -0.7 | -5.4 | 4.1 | -0.8 | 1.7 | 1.7 | 3.1 | -0.1 | -1.2 | 0.5 | -0.9 |
| សហរដ្ឋអាមេរិក | 2.2 | 1.1 | -2.5 | 2.7 | 1.8 | 2.1 | 1.8 | 2.3 | 2.6 | 2.3 | 2.4 | 2.7 |

Sources: International Monetary Fund, Economist and countries' statistic offices

តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៧-២០១៥ (កំណើនថ្លៃជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 10.5 | 19.7 | -0.5 | 4.1 | 5.5 | 3.0 | 3.0 | 4.5 | 4.9 | 4.0 | 2.2 | 1.0 |
| ឥណ្ឌូណេស៊ី | 6.4 | 10.1 | 4.7 | 5.1 | 5.4 | 4.3 | 7.0 | 7.7 | 7.1 | 4.3 | 6.5 | 6.6 |
| ម៉ាឡេស៊ី | 2.0 | 5.3 | 0.4 | 1.7 | 3.2 | 1.7 | 2.1 | 3.5 | 3.3 | 3.0 | 2.8 | 0.7 |
| សិង្ហបុរី | 2.1 | 6.5 | 0.5 | 2.9 | 5.2 | 4.6 | 2.3 | 1.0 | 2.3 | 0.9 | -0.1 | -0.3 |
| ថៃ | 2.2 | 5.5 | -0.9 | 3.1 | 3.8 | 3.0 | 2.2 | 2.0 | 2.5 | 2.0 | 1.1 | -0.5 |
| វៀតណាម | 8.3 | 23.3 | 7.3 | 9.0 | 18.6 | 9.3 | 6.6 | 4.8 | 4.7 | 4.5 | 5.4 | 0.7 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 4.8 | 5.9 | -0.8 | 3.2 | 5.4 | 2.7 | 2.6 | 2.1 | 2.2 | 2.0 | 1.5 | 1.2 |
| ហុងកុង | 2.0 | 4.3 | -0.3 | 2.4 | 5.3 | 4.1 | 4.0 | 4.1 | 3.6 | 4.9 | 5.0 | 4.4 |
| កូរ៉េខាងត្បូង | 2.5 | 4.6 | 2.8 | 3.0 | 4.4 | 2.1 | 1.1 | 1.1 | 1.6 | 1.4 | 1.0 | 0.6 |
| តៃវ៉ាន់ | 1.8 | 3.2 | -1.1 | 1.0 | 1.4 | 1.9 | 0.8 | 1.1 | 1.6 | 1.5 | 1.6 | 2.9 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 2.1 | 3.3 | 0.4 | 1.6 | 2.7 | 2.5 | 1.4 | 0.6 | 0.6 | 0.4 | 0.2 | -0.3 |
| ជប៉ុន | 0.1 | 1.4 | -1.3 | -0.7 | 0.1 | -0.03 | 0.4 | 1.5 | 3.6 | 3.4 | 2.6 | 2.3 |
| សហរដ្ឋអាមេរិក | 2.9 | 3.8 | -0.4 | 1.7 | 3.2 | 2.1 | 1.5 | 1.4 | 2.1 | 1.8 | 1.3 | -0.4 |

Sources: International Monetary Fund, Economist and National Institute of Statistics

តារាង៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារអាមេរិកនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៧-២០១៥ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា (រៀល) | 4062.7 | 4054.2 | 4140.5 | 4187.1 | 4063.6 | 4037.8 | 5369.6 | 3993.8 | 4026.9 | 4059.5 | 4070.1 | 4042.2 |
| ឥណ្ឌូណេស៊ី (រូពីយ៉ា) | 9419 | 9699 | 10413.8 | 9089.9 | 4374.0 | 9363.0 | 13892.2 | 11765.8 | 11615.3 | 11775.7 | 12244.1 | 12809.9 |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.3 | 3.3 | 3.5 | 3.2 | 1.5 | 3.1 | 4.2 | 3.3 | 3.2 | 3.2 | 3.4 | 3.6 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.51 | 1.42 | 1.5 | 1.4 | 1.3 | 1.2 | 1.7 | 1.3 | 1.3 | 1.3 | 1.3 | 1.4 |
| ថៃ (បាត) | 32.22 | 33.36 | 34.3 | 31.7 | 30.5 | 31.1 | 41.0 | 32.6 | 32.4 | 32.1 | 32.7 | 32.6 |
| វៀតណាម (ដុង) | 16030.0 | 16382 | 17725.2 | 19200.8 | 20574.3 | 20856.9 | 27987.1 | 21093.8 | 20923.2 | 21221.9 | 21314.0 | 21372.9 |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន (យ៉ន់) | 8.03 | 6.94 | 6.8 | 6.8 | 6.5 | 6.3 | 8.2 | 6.1 | 6.2 | 6.2 | 6.1 | 6.2 |
| ហុងកុង (ដុល្លារហុងកុង) | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 10.3 | 7.8 | 7.8 | 7.8 | 7.8 | 7.8 |
| កូរ៉េខាងត្បូង (វ៉ុន) | 929.0 | 1137.2 | 1277.8 | 1156.3 | 1108.6 | 1126.6 | 1460.0 | 1069.7 | 1028.9 | 1027.5 | 1088.4 | 1101.7 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 32.9 | 31.5 | 33.0 | 31.3 | 29.4 | 29.6 | 39.6 | 30.3 | 30.1 | 30.0 | 30.9 | 31.6 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 0.7 | 0.8 | 0.7 | 0.8 | 0.7 | 0.8 | 1.0 | 0.7 | 0.7 | 0.8 | 0.8 | 0.9 |
| ជប៉ុន (យ៉េន) | 117.8 | 102.5 | 93.6 | 87.8 | 79.9 | 79.8 | 130.2 | 102.8 | 102.1 | 104.0 | 114.6 | 119.2 |

Sources: International Monetary Fund, Economist and National Bank of Cambodia

តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០៧-២០១៥ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| ពោត (US No. 2) - USA (USD/តោន) | 163.7 | 223.1 | 165.5 | 185.9 | 291.7 | 298.4 | 259.4 | 209.9 | 214.0 | 174.1 | 173.5 | 174.2 |
| ដូងប្រេង-អឺរ៉ុបពាយព្យ (USD/តោន) | 780.3 | 948.5 | 682.8 | 900.8 | 1125.4 | 999.3 | 856.9 | 911.3 | 887.1 | 772.0 | 715.3 | 627.9 |
| កៅស៊ូ SMR 5 (USD/តោន) | 0.0 | 1431.6 | 1884.8 | 3405.7 | 4630.6 | 3200.7 | 2575.3 | 2034.7 | 1777.6 | 1672.1 | 1538.1 | 1450.2 |
| អង្ករ (Thai 100%B) - បាងកក (USD/តោន) | 305.4 | 615.3 | 524.5 | 506.6 | 558.5 | 594.8 | 533.8 | 450.7 | 411.7 | 447.0 | 430.3 | 426.0 |
| សណ្តែកសៀង (US No. 1) - USA (USD/តោន) | 384.0 | 522.8 | 436.9 | 449.8 | 540.7 | 591.4 | 538.4 | 552.3 | 517.8 | 457.3 | 439.7 | 363.9 |
| ប្រេងឆៅ - OPEC spot (USD/ធុង) | 66.8 | 99.4 | 57.7 | 76.8 | 106.2 | 109.5 | 105.9 | 104.7 | 105.9 | 100.8 | 73.4 | 50.9 |
| សាំង - US Gulf Coast (សេន/លីត្រ) | 52.2 | 68.1 | 40.8 | 53.3 | 71.9 | 74.6 | 71.2 | 70.1 | 74.1 | 70.0 | 48.3 | 40.1 |
| ម៉ាស៊ូត (ស្តាន់ដ័រតិច លេខ២) - US Gulf Coast (សេន/លីត្រ) | 55.5 | 76.2 | 43.0 | 56.1 | 75.7 | 80.7 | 78.4 | 77.5 | 77.1 | 73.7 | 57.5 | 44.6 |

Sources: Food and Agriculture Organisation and US Energy Information Administration

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្នុងប្រទេស

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

នៅត្រីមាសទី២ ឆ្នាំ២០១៥ វិនិយោគគិតជាទ្រព្យសកម្មជាប់លាប់ រួមចុះ ៩១,១% ធៀបនឹងត្រីមាសមុន និង ៣៣,២% ធៀបមួយឆ្នាំមុន មកត្រឹម ២៥៤,៦លានដុល្លារ។ វិនិយោគក្នុងវិស័យកសិកម្ម កើន ៤៧,៤% ធៀបត្រីមាសមុន ដល់ ៣៨,១លានដុល្លារ និងមានចំណែក ១៥,០% នៃវិនិយោគសរុប។ វិនិយោគក្នុងវិស័យឧស្សាហកម្ម រួមចំណែក ៥១,៤% នៃវិនិយោគសរុប។ វិនិយោគក្នុងវិស័យកាត់ដេរ ធ្លាក់ចុះ ៣៣,៦% ធៀបត្រីមាសមុន មកត្រឹម ៤២,៤លានដុល្លារ។ វិនិយោគក្នុងវិស័យសេវាកម្ម រួមចំណែក ៣៣,៦% នៃវិនិយោគសរុប ប៉ុន្តែក្នុងត្រីមាសទី២នេះ គ្មានអនុមតិវិនិយោគក្នុងអនុវិស័យសណ្ឋាគារ និងទេសចរណ៍ទេ។

នៅត្រីមាសទី២ ឆ្នាំ២០១៥ ភ្ញៀវទេសចរបរទេសមកដល់កម្ពុជាសរុប ធ្លាក់ចុះ ២៧,៦% ធៀបនឹងត្រីមាសមុន ប៉ុន្តែកើន ៦,៥% បើធៀបនឹងត្រីមាសដូចគ្នា កាលពីឆ្នាំមុន។ ភ្ញៀវមកដល់តាមផ្លូវអាកាស ធ្លាក់ចុះ ៣១,៤% ហើយតាមផ្លូវគោក និងផ្លូវទឹក ធ្លាក់ចុះ ២៣,៣% ធៀបនឹងត្រីមាសមុន។ ចំនួនភ្ញៀវមកពីប្រទេសប្រភពទេសចរចម្បងគេសម្រាប់កម្ពុជា ដូចជា វៀតណាម ចិន និងកូរ៉េខាងត្បូង បានថយចុះ។ ការកើតរាលដាលជំងឺ Middle East respiratory syndrome (MERS) អាចជាដើមហេតុមួយនៃការថយចុះនេះ។

ការនាំចេញសរុប កើន ០,៥៥% ធៀបនឹងត្រីមាសមុន និង ១៧,៣% ធៀបឆ្នាំមុន។ ការនាំចេញសម្លៀកបំពាក់ កើន ៣,៤២% ធៀបនឹងត្រីមាសមុន ពី ១៥៤៨,៨លានដុល្លារ ដល់ ១៦០១,៧លានដុល្លារ។ ការនាំចេញទៅសហភាពអឺរ៉ុប និងសហរដ្ឋអាមេរិក កើន ១១,១% និង ០,៧% រៀងគ្នា ធៀបនឹងត្រីមាសមុន ប៉ុន្តែការនាំចេញទៅប្រទេសសមាជិកអាស៊ាន ធ្លាក់ចុះ ០,៨% និងទៅប្រទេសជប៉ុន ធ្លាក់ចុះ ២២,៩% ។ ការនាំចេញផលិតផលកសិកម្មធ្លាក់ចុះ ១៩,១% ធៀបនឹងត្រីមាសមុន ក្នុងនោះ ការនាំចេញឈើធ្លាក់ចុះ ២៩,៤% កៅស៊ូធ្លាក់ចុះ ១,៨% អង្ករធ្លាក់ចុះ ១៩,១% ហើយផលិតផលកសិកម្មផ្សេងទៀតធ្លាក់ចុះ ២១,៧%។

នៅត្រីមាសទី២ ឆ្នាំ២០១៥ ការនាំចូល រួមចុះ ៧,៥% ធៀបនឹងត្រីមាសមុន និង ១៩,០% ធៀបឆ្នាំមុន មកត្រឹម ២៩២០,៣លានដុល្លារ។ ការនាំចូលសាំង កើន ៤,៨% ហើយការនាំចូលសម្ភារសំណង់ កើន ២២,៤% ប៉ុន្តែការនាំចូលម៉ាស៊ូត ធ្លាក់ចុះ ៧,៨%។

---

អត្ថបទនេះ រៀបរៀងដោយលោកស្រី ស្រ៊ី បុប្ផារ័ត្ន ជាអ្នកស្រាវជ្រាវ និងលោកស្រី ប៊ុន ដូរីណា ជាជំនួយការស្រាវជ្រាវ នៅវិទ្យាស្ថាន CDRI។

**ហិរញ្ញវត្ថុសាធារណៈ**

នៅត្រីមាសទី២ ឆ្នាំ២០១៥ ចំណូលរដ្ឋាភិបាលសរុប កើន ២៥,៤% ធៀបនឹងត្រីមាសមុន ដល់ ៣៣០១,៦ប៊ីលានរៀល ក្នុងនោះ ចំណូលចរន្ត កើន ២៤,៨% ដល់ ៣២៧៤,៥ប៊ីលានរៀល។ ចំណូលពន្ធ កើន ២៤,៤% ដល់ ៣០០៦,១ប៊ីលានរៀល ដោយរួមចំណែកបាន ៩១,០% ក្នុងចំណូលរដ្ឋាភិបាលសរុប។ ចំណូលមិនមែនពន្ធ កើន ២៩,៨% ដល់ ២៦៨,៥ប៊ីលានរៀល។ នៅត្រីមាសដដែល ចំណាយសរុប ធ្លាក់ចុះ ១៦,៥% ធៀបនឹងត្រីមាសមុន មកត្រឹម ១៧៣៧,២ប៊ីលានរៀល ដោយសារការធ្លាក់ចុះ ៤៣,១% នៃចំណាយមូលធន មកត្រឹម ៣៧១,៣ប៊ីលានរៀល និង ការធ្លាក់ចុះ ៤,៤% នៃចំណាយចរន្ត មកត្រឹម ១៣៦៥,៩ប៊ីលានរៀល។

**អតិផរណា និងអត្រាប្តូរប្រាក់**

នៅត្រីមាសទី២ ឆ្នាំ២០១៥ ថ្លៃទំនិញសរុប កើន ១,០% ធៀបនឹងឆ្នាំមុន។ ថ្លៃស្បៀងអាហារ និងភេសជ្ជៈមិនមែនស្រា កើន ៣,៩% រីឯថ្លៃដឹកជញ្ជូនធ្លាក់ចុះ ៧,៩%។ ប្រាក់រៀល ធ្លាក់ថ្លៃ ០,៤% ទល់នឹងប្រាក់ដុល្លារ ប៉ុន្តែឡើងថ្លៃ ១,៤% ទល់នឹងប្រាក់បាតថៃ និង ១,០% ទល់នឹងប្រាក់ដុងវៀតណាម ធៀបនឹងត្រីមាសមុន។ មាស ធ្លាក់ថ្លៃ ៤,៣% ធៀបត្រីមាសមុន ប៉ុន្តែម៉ាស៊ូតឡើងថ្លៃ ៥,៥% ហើយសាំង ឡើងថ្លៃ ៥,១%។

**ស្ថានភាពក្រីក្រ**

នៅខែសីហា ២០១៥ ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់អ្នករើសអេតចាយ កម្មករកាត់ដេរ អ្នកជាក់ស៊ីក្លូ អ្នកស៊ីឈ្នួលធ្វើស្រែ អ្នករត់ម៉ូតូឌុប អ្នកបម្រើភោជនីយដ្ឋាន និង អ្នកលីសែង បានកើនឡើង ធៀបនឹងខែសីហា ឆ្នាំមុន រីឯប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់ ៣ក្រុមពលករងាយរងគ្រោះផ្សេងទៀត ធ្លាក់ចុះ។

គិតចាប់ពីខែមិថុនា ២០១៥ មក មានតែ ២ក្រុមពលករងាយរងគ្រោះប៉ុណ្ណោះ ដែលកើនប្រាក់ចំណូល។ អ្នកស៊ីឈ្នួលធ្វើស្រែអាចរកការងារបានច្រើនជាងមុន ហើយកើនចំណូល ២២% ដល់ ៩៨៦៩រៀល/ថ្ងៃ។ អ្នកផ្តល់សម្ភាសន៍ ៧៥% ប្រាប់ថា ពួកគេជាប្រភពចំណូលចម្បងសម្រាប់គ្រួសារខ្លួន។ ពួកគេ ៤៥% ក៏រកចំណូលពីប្រភពផ្សេងទៀត ដូចជា ការបេះប្រមូលធនធានរួម និងការលក់ពលកម្មនៅកន្លែងផ្សេងទៀត។ ពួកគេ ៥៥% ទទួលកម្ចីពីសាច់ញាតិ ឬអ្នកចងការប្រាក់។

ចំណូលប្រចាំថ្ងៃរបស់កម្មករកាត់ដេរ កើន ៤,៨% ដល់ ១៥.៥១៥រៀល។ ជាមធ្យម ពួកគេរៀនបានត្រឹមថ្នាក់ទី៦ ហើយមានតែ ១៩% ប៉ុណ្ណោះ ដែលបានចូលរៀនវគ្គកាត់ដេរមុនពេលចាប់ផ្តើមការងារ រីឯអ្នកផ្សេងទៀត ទទួលបានការបណ្តុះបណ្តាលភ្ជាប់នឹងការងារតែម្តង។ ជាមធ្យម កម្មករកាត់ដេរ ធ្វើការ ៦ថ្ងៃ ឬ ៥៥ម៉ោង/សប្តាហ៍។ កម្មករកាត់ដេរចំណាយសរុបអស់ ៣៩% នៃចំណូលរបស់ខ្លួន ក្នុងនោះចំណាយលើអាហារមាន ៧០% និងថ្លៃជួលផ្ទះ ១៨%។ ពួកគេ ៧៣% មិនអាចសន្សំប្រាក់សម្រាប់ថ្ងៃអនាគតឡើយ។ អ្នកផ្តល់សម្ភាសន៍ ៤១រូប ប្រាប់ថា ប្រសិនបើរោងចក្រកាត់ដេរត្រូវបិទទ្វារ ពួកគេនឹងត្រឡប់ទៅផ្ទះវិញ។

នៅខែសីហា ២០១៥ ចំណូលរបស់អ្នកលក់បន្លែ ធ្លាក់ចុះ ២១% ធៀបនឹងអង្កេតលើកមុន មកត្រឹម ១៤.៤២៣រៀល/ថ្ងៃ ដែលជាការធ្លាក់ចុះខ្លាំងបំផុត បើធៀបនឹងក្រុមផ្សេងទៀត។ មានតែអ្នកលក់បន្លែ ១០% ប៉ុណ្ណោះ ដែលរស់នៅក្នុងរាជធានីភ្នំពេញ រីឯអ្នកដទៃទៀត ភាគច្រើនមកពីខេត្តកណ្តាល និងព្រៃវែង។ អ្នកលក់បន្លែ៧៣%មកលក់តែម្នាក់ឯង។ពួកគេជួលផ្ទះស្នាក់នៅរួមគ្នាដោយជាមធ្យមមានគ្នាបួននាក់។ ពួកគេចំណាយជាមធ្យម ៣០% នៃចំណូលសរុបរបស់ខ្លួន ហើយក្នុងនោះចំណាយលើស្បៀងអាហារ មានដល់ ៩៤%។ ពួកគេ មិនអាចសន្សំប្រាក់ដើម្បីពង្រីកអាជីវកម្មបានទេព្រោះចំណូលរកបានមិនទាំងគ្រប់សម្រាប់ទ្រទ្រង់ជីវភាពគ្រួសារផង។

ចំណូលរបស់អ្នករើសអេតចាយ ធ្លាក់ចុះ ១៤% មកត្រឹម ១២.២៣៧រៀល/ថ្ងៃ ដោយសារកំណើនចំនួនអ្នករើសអេតចាយនៅតំបន់ចាក់សម្រាម។ អ្នកផ្តល់សម្ភាសន៍ ៨៨% ប្រាប់ថា ពួកគេមករាជធានីភ្នំពេញជាមួយគ្រួសារហើយ៣២%ត្រូវត្រឡប់ទៅភូមិកំណើតវិញម្តងម្កាល ដើម្បីស៊ីឈ្នួលធ្វើស្រែចំការ នៅពេលពួកគេមិនអាចរកចំណូលបានច្រើននៅរាជធានីភ្នំពេញ។ ជាមធ្យម អ្នករើសអេតចាយ ចាយវាយអស់ ៣១% នៃចំណូលសរុបរបស់ខ្លួនជាពិសេសទៅលើអាហារ។ ចំណាយលើកន្លែងស្នាក់នៅ មានជាមធ្យម ៣៧.០០០រៀល/ខែ។

ចំណូលប្រចាំថ្ងៃរបស់កម្មករសំណង់គ្មានជំនាញ ធ្លាក់ចុះ ៩,៩% មកត្រឹម ១៣.៩១៦រៀល ដោយសារការងារមានតិចជាងមុន ហើយកម្មករមានចំនួនច្រើនជាងមុន។ កម្មករផ្តល់សម្ភាសន៍ចេញមកពីខេត្តព្រៃវែង និងស្វាយរៀង។ ពួកគេជាប្រភពចំណូលចម្បងក្នុងគ្រួសារ ហើយប្រាក់ចំណូលរបស់ពួកគេអាចជួយទ្រទ្រង់គ្រួសារបានខ្លះៗ។ ពួកគេចាយវាយប្រចាំថ្ងៃអស់ ៣៧% នៃចំណូលសរុប ហើយភាគច្រើនទៅលើម្ហូបអាហារ។

ចំណូលរបស់អ្នកលីសែង ធ្លាក់ចុះ ៩,៣% ធៀបនឹងអង្កេតលើកមុន មកត្រឹម ១៤.៣១៤រៀល/ថ្ងៃ។ អ្នកឆ្លើយសម្ភាសន៍ទាំងអស់ សុទ្ធតែមកពីខេត្ត ហើយភាគច្រើនមកពីខេត្តព្រៃវែង (៧០%)។ ពួកគេស្នាក់នៅរួមគ្នាជាមធ្យម ៦នាក់ ហើយបង់ថ្លៃជួលកន្លែងស្នាក់នៅអស់ ៦៥.០០០រៀល/ខែ។ ពួកគេចំណាយភាគច្រើនទៅលើម្ហូបអាហារ គឺរហូតដល់ ៣៧% នៃចំណូលសរុប ហើយមាន ៦០% ប្រាប់ថា បានសន្សំប្រាក់ខ្លះដើម្បីជួយទ្រទ្រង់ដល់គ្រួសារក្នុងការចិញ្ចឹមសត្វនៅផ្ទះ។

ចំណូលប្រចាំថ្ងៃរបស់អ្នកបម្រើភោជនីយដ្ឋាន ធ្លាក់ចុះ ៧,៣% មកត្រឹម ៨១០០រៀល។ អ្នកឆ្លើយតប ៩៣% ប្រាប់ថា ពួកគេស្នាក់នៅកន្លែងធ្វើការ។ ពួកគេចាយវាយប្រចាំថ្ងៃតែទៅលើម្ហូបអាហារប៉ុណ្ណោះ ដែលស្មើនឹង ២៩% នៃចំណូលសរុបរបស់ខ្លួន។ ពួកគេមិនអាចសន្សំប្រាក់ទុកបានឡើយ ព្រោះត្រូវផ្ញើប្រាក់នៅសល់ពីការចាយវាយ ទៅឲ្យគ្រួសារ។ ទោះយ៉ាងណាក្តី ប្រាក់នោះអាចជួយទ្រទ្រង់គ្រួសារបានតែមួយផ្នែកប៉ុណ្ណោះ។

# តាមដានសេដ្ឋកិច្ច - សូចនាករ

## តារាង១. គម្រោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ២០០៨-១៥*

| | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | | | | | | |
| កសិកម្ម | 92 | 615.0 | 530.7 | 725 | 531.6 | 930.5 | 28.9 | 27.6 | 0.0 | 0.0 | 25.8 | 38.08 |
| ឧស្សាហកម្ម | 724.9 | 818.5 | 403.7 | 2860.1 | 829.3 | 3257 | 179.0 | 239.3 | 434.3 | 149.9 | 342.8 | 130.91 |
| *កាត់ដេរ* | 142.8 | 90.1 | 122.8 | 393.9 | 497 | 324.1 | 109.3 | 172.4 | 81.6 | 30.3 | 63.9 | 42.4 |
| សេវាកម្ម | 10003.2 | 4432.0 | 1337.3 | 3425.4 | 916.6 | 140.7 | 219.1 | 114.4 | 191.5 | 0.0 | 2504.6 | 85.64 |
| *សណ្ឋាគារ និងទេសចរណ៍* | 8758.1 | 3980.1 | 1105.1 | 2850.9 | 691.5 | 106 | 163.3 | 15.4 | 268.1 | 0.0 | 60.6 | 0.0 |
| សរុប | 10570.9 | 5865.5 | 2271.7 | 7010.42 | 2278.0 | 4328 | 426.9 | 302.2 | 625.8 | 149.9 | 2873.2 | 254.6 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | - | -75.8 | -29.2 | 64.1 | -76.0 | 1816.8 | -91.1 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 308.6 | -44.5 | -61.3 | 209 | -67.5 | 90.1 | 95.1 | -81.8 | 142.7 | -91.5 | 573.0 | -33.2 |

* Including expansion project approvals. Source: Cambodian Investment Board

## តារាង២. តម្លៃគម្រោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ២០០៨-១៥

| | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| | លានដុល្លារ | | | | | | | | | | |
| ភូមិគ្រឹះ និងផ្ទះ | 376.2 | 213.9 | 220.1 | 405.1 | 547.3 | 658.9 | 133.6 | 84.0 | 33.1 | 20.4 | 122.3 |
| ផ្សេងៗ | 740.9 | 187.8 | 217.8 | 199.9 | 463.6 | 859.6 | 190.0 | 141.7 | 105.6 | 11.7 | 49.8 |
| សរុប | 1117.0 | 441.2 | 489.8 | 605.0 | 1010.9 | 1518.5 | 323.6 | 225.7 | 138.7 | 32.1 | 172.0 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | |
| សរុប | - | - | - | - | - | - | 34.3 | -30.2 | -38.5 | -77.8 | 437.3 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | |
| សរុប | 75.7 | -60.5 | 11.0 | 23.5 | 67.1 | 28.1 | 8.0 | -9.2 | -64.2 | -86.7 | -46.8 |

Source: Department of Cadastre and Geography of Phnom Penh municipality

## តារាង៣. ចំនួនអ្នកដំណើរបរទេសមកដល់ប្រទេសកម្ពុជា ឆ្នាំ២០០៨-១៥

| | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | ចំនួនអ្នកដំណើរ (ពាន់នាក់) | | | | | | | | | | | |
| តាមផ្លូវអាកាស | 1239.4 | 1111.7 | 1304.3 | 1480.4 | 1722.1 | 2017.7 | 699.0 | 438.2 | 497.5 | 638.8 | 725.1 | 497.4 |
| តាមផ្លូវគោក និងទឹក | 881.9 | 999.7 | 1094.6 | 1401.4 | 1862.2 | 2192.5 | 569.0 | 495.2 | 501.2 | 663.9 | 647.6 | 496.7 |
| សរុប | 2121.3 | 2111.5 | 2398.9 | 2881.8 | 3584.3 | 4210.2 | 1268.0 | 933.4 | 998.7 | 1302.7 | 1372.6 | 994.1 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | | 10.0 | -26.4 | 7.0 | 30.4 | 5.4 | -27.6 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 5.0 | -0.5 | 13.6 | 20.1 | 24.4 | 17.5 | 8.0 | 1.4 | 3.5 | 13.0 | 8.3 | 6.5 |

Source: Ministry of Tourism

## តារាង៤. ការនាំចេញ និងនាំចូល ឆ្នាំ២០០៨-១៥ *

| | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | លានដុល្លារ | | | | | | | | | | | |
| ការនាំចេញសរុប | 3097.8 | 2901.6 | 3630.2 | 4929.5 | 6106.4 | 6982.4 | 1976.5 | 1859.8 | 2132.5 | 2137.1 | 2170.1 | 2182 |
| ក្នុងនេះ៖ សម្លៀកបំពាក់ទៅ | 2986.2 | 2565.3 | 3223.4 | 4259.6 | 5015.4 | 5386.1 | 1464.0 | 1379.2 | 1624.7 | 1492.6 | 1548.8 | 1601.7 |
| - *សហរដ្ឋអាមេរិក* | 1908.3 | 1512.6 | 1853.9 | 2055.3 | 2143.3 | 2075.2 | 531.1 | 452.5 | 511.2 | 468.8 | 491.08 | 494.3 |
| - *សហភាពអឺរ៉ុប* | 689.0 | 644.7 | 809.5 | 1322.2 | 1716.9 | 1969.6 | 532.7 | 558.5 | 673.8 | 638.7 | 617.3 | 685.9 |
| - *អាស៊ាន* | 10.8 | 6.9 | 9.9 | 17.6 | 39.4 | 60.2 | 21.9 | 19.3 | 20.5 | 21.7 | 24.8 | 24.6 |
| - *ជប៉ុន* | 25.2 | 44.5 | 86.5 | 147.0 | 188.6 | 278.7 | 101.4 | 74.9 | 117.6 | 89.2 | 121.4 | 93.6 |
| - *ប្រទេសផ្សេងៗ* | 352.9 | 356.5 | 463.6 | 717.5 | 927.2 | 1002.9 | 277.0 | 273.9 | 301.6 | 274.2 | 294.2 | 303.4 |
| កសិកម្ម | 44.5 | 73.1 | 164.9 | 362.1 | 376.7 | 554.5 | 167.0 | 157.3 | 133.7 | 166.4 | 150.3 | 127.3 |
| - *កៅស៊ូ* | 35.8 | 51.6 | 89.1 | 197.6 | 176.6 | 175.2 | 31.7 | 40.0 | 34.8 | 47.5 | 41.7 | 40.9 |
| - *ឈើ* | 3.4 | 3.5 | 34.1 | 48.8 | 36.8 | 73.6 | 55.9 | 48.4 | 19.6 | 8.2 | 13.9 | 9.8 |
| - *ត្រី* | 2.3 | 3.9 | 2.8 | 3.1 | 2.0 | 1.2 | 0.3 | 0.2 | 0.1 | 0.2 | 0.2 | 0.2 |
| - *អង្ករ* | 2.6 | 10.9 | 34.7 | 106.6 | 146.4 | 262.3 | 57.9 | 52.8 | 55.8 | 82.0 | 89.5 | 72.4 |
| - *ផលិតផលកសិកម្មផ្សេងៗ* | 0.5 | 3.0 | 4.1 | 6.0 | 14.9 | 42.4 | 21.2 | 16.0 | 23.5 | 28.5 | 5.2 | 4.0 |
| ផ្សេងៗ | 67.1 | 263.2 | 242.0 | 307.9 | 714.4 | 1088.2 | 345.5 | 323.3 | 373.0 | 478.2 | 471.0 | 452.9 |
| ការនាំចូលសរុប ក្នុងនេះ៖ | 4272.0 | 4331.5 | 5190.6 | 6375.9 | 8593.3 | 8639.4 | 2238.2 | 2454.4 | 2794.8 | 2807.9 | 2717.3 | 2920.3 |
| សាំង | 84.9 | 91.13 | 108.6 | 294.4 | 308.0 | 306.4 | 77.4 | 83.2 | 80.2 | 93.9 | 34.5 | 92.2 |
| ម៉ាស៊ូត | 119.5 | 180.67 | 203.8 | 447.0 | 559.5 | 569.1 | 148.5 | 142.5 | 163.4 | 147.9 | 45.1 | 152.7 |
| សម្ភារសំណង់ | 56.3 | 49.74 | 57.6 | 48.1 | 66.1 | 80.8 | 27.8 | 29.2 | 29.0 | 31.6 | 12.4 | 42.0 |
| ផ្សេងៗ | 4011.8 | 4010.0 | 4820.6 | 5586.4 | 7659.1 | 7682.6 | 1984.5 | 2199.5 | 2522.2 | 2534 | 835.2 | 2633 |
| ជញ្ជីងពាណិជ្ជកម្ម | -1174.7 | -1429.9 | -1560.5 | -1446.4 | -1341.6 | -1610.9 | -261.7 | -589.5 | -662.3 | -670.8 | -547.2 | -738.3 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | - | - | - | - | - | - | 9.8 | -5.8 | 17.8 | -8.1 | 3.8 | 3.4 |
| ការនាំចេញសរុប | - | - | - | - | - | - | 8.9 | -5.9 | 14.7 | 0.2 | 1.5 | 0.5 |
| ការនាំចូលសរុប | - | - | - | - | - | - | 5.1 | 9.4 | 14.1 | 0.5 | -3.2 | 7.5 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | 1.6 | -14.1 | 25.7 | 32.1 | 17.7 | 7.4 | 19.5 | 9.6 | 3.6 | 11.9 | 5.8 | 16.1 |
| ការនាំចេញសរុប | 1.6 | -6.3 | 25.1 | 35.8 | 23.9 | 14.3 | 25.3 | 14.8 | 8.3 | 17.7 | 9.8 | 17.3 |
| ការនាំចូលសរុប | 13.3 | 1.4 | 19.8 | 22.8 | 16.8 | 0.5 | 2.1 | 10.8 | 35.7 | 31.8 | 21.4 | 19.2 |

* Import data include tax-exempt imports.
Sources: Department of Trade Preference Systems, Ministry of Commerce and Customs and Excise Department, MEF (website)

## តារាង៥. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានសាច់ប្រាក់ ឆ្នាំ២០០៨-១៥ (ប៊ីលានរៀល)

| | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| ចំណូលសរុប | 5290.0 | 4885.2 | 5989.0 | 6251.4 | 7691.9 | 8255.2 | 2220.5 | 2793.7 | 2580.6 | 2948.6 | 2633.5 | 3301.6 |
| ចំណូលចរន្ត | 5210.7 | 4855.9 | 5859.1 | 6179.3 | 7443.8 | 8233.2 | 2219.2 | 2765.2 | 2571.4 | 2803.6 | 2623.7 | 3274.5 |
| ចំណូលពន្ធ | 4409.9 | 4268.0 | 4693.0 | 5277.5 | 6334.8 | 7198.1 | 1988.7 | 2383.1 | 2264.6 | 2358.8 | 2416.8 | 3006.1 |
| ពន្ធក្នុងស្រុក | 3248.4 | 3088.6 | 3533.6 | 4071.6 | 5002.8 | 5728.1 | 1593.6 | 1943.2 | 1798.0 | 1891.6 | 2002.8 | 2474.6 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | 1161.5 | 1064.7 | 1159.4 | 1205.9 | 1331.7 | 1470.0 | 449.0 | 439.9 | 466.5 | 467.2 | 414.0 | 524.5 |
| ចំណូលមិនមែនពន្ធ | 800.8 | 702.1 | 1166.1 | 901.8 | 1118.2 | 1035.2 | 176.6 | 382.1 | 306.9 | 444.8 | 206.9 | 268.5 |
| ចំណូលលើទ្រព្យសម្បត្តិ | 78.0 | 64.6 | 291.1 | 63.8 | 143.0 | 84.0 | 11.1 | 40.8 | 21.2 | 15.4 | 3.0 | 16.7 |
| លក់ទំនិញ និងសេវា | 424.7 | 408.0 | 460.1 | 588.7 | 667.4 | 750.3 | 160.3 | 197.5 | 212.9 | 300.5 | 189.2 | 219.2 |
| ចំណូលមិនមែនពន្ធផ្សេងទៀត | 298.2 | 228.2 | 408.9 | 249.3 | 298.8 | 200.8 | 5.2 | 143.7 | 72.7 | 128.9 | 14.7 | 32.6 |
| ចំណូលជាមូលធន | 79.3 | 29.3 | 129.9 | 72.1 | 247.9 | 73.4 | 1.3 | 28.5 | 9.2 | 145.0 | 9.8 | 27.1 |
| ចំណាយសរុប | 6297.8 | 7383.5 | 8784.6 | 9032.4 | 9660.9 | 12535.7 | 2618.8 | 2867.2 | 3349.0 | 4471.4 | 1958.1 | 1737.2 |
| ចំណាយជាមូលធន | 2574.4 | 2694.9 | 2853.2 | 3546.9 | 3628.3 | 5567.5 | 1187.1 | 1395.9 | 1421.7 | 1586.0 | 529.4 | 371.3 |
| ចំណាយចរន្ត | 3809.0 | 4440.0 | 4773.1 | 5341.2 | 6188.4 | 6968.3 | 1431.7 | 1471.4 | 1927.3 | 2885.4 | 1428.7 | 1365.9 |
| បៀវត្សរ៍ | 1397.0 | 2012.0 | 2048.8 | 2170.6 | 2486.6 | 2997.3 | 860.0 | 931.0 | 918.4 | 1046.1 | 935.1 | 945.8 |
| ឧបត្ថម្ភធន និងជំនួយសង្គមកិច្ច | 927.1 | 871.4 | 1099.4 | 1518.8 | 1586.8 | 1563.0 | 213.1 | 259.6 | 434.8 | 719.5 | 194.3 | 207.2 |
| ចំណាយចរន្តផ្សេងទៀត | 1384.9 | 1556.6 | 1624.8 | 1651.8 | 2115.1 | 2408.0 | 358.6 | 280.8 | 574.1 | 1119.9 | 299.3 | 201.1 |
| សមតុល្យជាទូទៅ | -1007.8 | -2498.3 | -2795.7 | -1271.4 | -1969.0 | -4280.6 | -398.4 | -73.5 | -768.5 | -522.8 | 675.5 | 1564.4 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 2055.1 | 1746.1 | 1845.2 | -2781.0 | 2457.8 | 4326.2 | 977.9 | 1123.9 | 1012.5 | 857.9 | 232.2 | 116.7 |
| ហិរញ្ញប្បទានក្នុងស្រុក | -127 | 474.9 | 938.6 | 2379.2 | -332.9 | 824.4 | -915.0 | -172.9 | -279.3 | -61.4 | -687.8 | -1159.4 |

Source: Ministry of Economy and Finance website

## តារាង៦. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្ដូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ២០០៨-១៥

| | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| (តុលា-ធ្នូ ២០០៦:១០០) | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ភ្នំពេញ - ទំនិញគ្រប់មុខ | 19.7 | -0.7 | 4.1 | 5.4 | 2.3 | 3.9 | 4.6 | 4.8 | 4.0 | 2.1 | 1.0 | 1.0 |
| - អាហារ និងភេសជ្ជៈមិនមែនស្រា | 33.1 | -0.3 | 4.4 | 6.5 | 2.5 | 4.9 | 5.7 | 5.3 | 5.1 | 3.4 | 4.2 | 3.9 |
| - ដឹកជញ្ជូន | 19.4 | -10.7 | 7.0 | 6.9 | 3.3 | -1.0 | -1.1 | 0.5 | -0.2 | -3.3 | -10.9 | -7.9 |
| | អត្រាប្ដូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 4058.2 | 4140.5 | 4187.1 | 4063.6 | 4039.2 | 4036.2 | 3993.8 | 4026.9 | 4059.5 | 4064.7 | 4042.2 | 4056.7 |
| រៀលក្នុង ១ បាតថៃ | 123.5 | 121.1 | 133.1 | 133.2 | 130.0 | 124.9 | 123.0 | 124.8 | 127.1 | 124.6 | 124.4 | 122.6 |
| រៀលក្នុង ១០០ ដុងវៀតណាម | 24.8 | 23.4 | 21.7 | 19.7 | 19.4 | 19.1 | 19.1 | 19.2 | 19.2 | 19.1 | 19.0 | 18.8 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 105.9 | 113.1 | 147.5 | 184.5 | 200.9 | 152.3 | 156.6 | 155.9 | 155.5 | 141.1 | 150.9 | 144.4 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 4555.2 | 3170.9 | 3859.3 | 4761.2 | 4941.2 | 4852.1 | 4971.2 | 5006.7 | 5047.6 | 4382.8 | 3823.4 | 4032.0 |
| ថ្លៃសាំង (រៀល/លីត្រ) | 4750.8 | 3593.1 | 4368.1 | 5044.5 | 5312.7 | 5083.3 | 5171.5 | 5200.0 | 5348.6 | 4613.0 | 3986.2 | 4189.0 |

Sources: National Institute of Statistics, National Bank of Cambodia and CDRI

## តារាង៧. ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០០៨-១៥ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | ប៊ីលានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 10345.0 | 14655.0 | 16697.9 | 17893.9 | 18154.5 | 21260.1 | 23344.4 | 26235.8 | 26817.8 | 26699.7 | 26823 | 27975.3 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | 1513.3 | 1573.0 | 2778.9 | 5760.8 | 10437.4 | 11508.3 | 11817.4 | 12024.4 | 13950.5 | 15859.8 | 16863.2 | 18178.3 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | -2987.0 | -2252.0 | -2126.6 | -2123.1 | -2486.4 | -2794.9 | -3349.3 | -3747.3 | -4113.0 | -4359.1 | -5064 | -5666.1 |
| ឥណទានដល់ផ្នែកឯកជន | 9894.0 | 10532.0 | 13331.2 | 17552.8 | 23536.6 | 27608.8 | 28584.5 | 30621.3 | 33226.4 | 36244.6 | 37759.4 | 40995 |
| រូបិយវត្ថុទូទៅ M2 | 11858.0 | 16228.0 | 19476.8 | 23654.7 | 28591.9 | 32768.4 | 35161.8 | 38259.9 | 40768.3 | 42559.5 | 43685.2 | 46153.7 |
| រូបិយវត្ថុ M1 | 2399.0 | 3120.0 | 3220.9 | 3956.2 | 4045.7 | 4878.2 | 5376.2 | 5231.3 | 5583.1 | 6308.4 | 6628.0 | 6293.1 |
| រូបិយវត្ថុផ្សេងៗ | 9459.0 | 13108.0 | 16255.9 | 19698.5 | 24546.2 | 27890.2 | 29785.7 | 33028.5 | 35185.2 | 36251.1 | 37058.2 | 39860.6 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ M2 | 4.8 | 36.9 | 20.0 | 17.8 | 20.9 | 14.6 | 15.4 | 20.8 | 38.9 | 29.9 | 24.2 | 20.6 |
| រូបិយវត្ថុ M1 | 16.9 | 30.1 | 3.2 | 16.9 | 2.3 | 20.6 | 19.5 | 14.1 | 18.3 | 29.3 | 23.3 | 20.3 |
| រូបិយវត្ថុផ្សេងៗ | 2.2 | 38.6 | 24.0 | 17.9 | 44.6 | 13.6 | 14.6 | 22.0 | 42.8 | 30.0 | 24.4 | 20.7 |

Source: National Bank of Cambodia

## តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បម្រែបម្រួលជាភាគរយធៀបឆ្នាំមុន | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2012 | 2013 | 2014 | | | | 2015 | | | 2015 | | |
| | | | កុម្ភៈ | ឧសភា | សីហា | វិច្ឆិកា | កុម្ភៈ | ឧសភា | សីហា | កុម្ភៈ | ឧសភា | សីហា |
| អ្នកធាក់ស៊ីក្លូ | 10303 | 10,438 | 10,832 | 10764 | 9867 | 11634 | 12950 | 12467 | 11799 | 19.6 | 15.8 | 19.6 |
| អ្នកលីសែង | 12143 | 13247 | 12141 | 12590 | 13399 | 16189 | 16798 | 15782 | 14314 | 38.4 | 25.4 | 6.8 |
| អ្នកលក់បន្លែតូចតាច | 10771 | 11366 | 12294 | 13581 | 15373 | 17735 | 15007 | 18171 | 14423 | 22.1 | 33.6 | -6.2 |
| អ្នករើសអេតចាយ | 8680 | 9819 | 9593 | 9214 | 8337 | 9548 | 10627 | 14169 | 12237 | 10.8 | 53.8 | 46.8 |
| អ្នកបម្រើភោជនីយដ្ឋាន* | 6111 | 6697 | 7449 | 6696 | 7565 | 9435 | 8466 | 8742 | 8100 | 13.7 | 30.3 | 7.1 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 6151 | 6599 | 8932 | 5836 | 8494 | 6781 | 8,303 | 8063 | 9869 | -7.0 | 37.9 | 16.2 |
| កម្មកររោងចក្រកាត់ដេរ | 8932 | 10161 | 9548 | 11412 | 11607 | 12092 | 14644 | 14803 | 15515 | 53.4 | 29.7 | 33.7 |
| អ្នករត់ម៉ូតូឌុប | 12930 | 13450 | 13227 | 13401 | 12656 | 14259 | 14549 | 14692 | 14124 | 10 | 9.6 | 11.6 |
| កម្មករសំណង់គ្មានជំនាញ | 11078 | 13184 | 15162 | 15343 | 15401 | 15437 | 16678 | 15453 | 13916 | 10 | 0.7 | -9.6 |
| កម្មករសំណង់មានជំនាញ | 13743 | 15442 | 15163 | 15792 | 20420 | 18303 | 17050 | 19918 | 18905 | 12.4 | 26.1 | -7.4 |

* Waitresses' earnings do not include meals and accommodation provided by shop owners. Surveys on the incomes of waitresses, rice-field workers, garment workers, motorcycle taxi drivers and construction workers began in February 2000. Source: CDRI